សុន្ទរកថារបស់ **លោក វ៉ាដា តាកាយូគ**

លេខាទីពីរ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាយុត្តិធម៌ និងសាលាបឋមសិក្សាសំណាងព្រះស្រី

ក្នុងស្រុកបវិល ខេត្តបាត់ដំបង ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤

**សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ!**

**សូមគោរព ឯកឧត្តម ងួន រតនៈ អភិបាលរងខេត្តបាត់ដំបង!**

**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីចូលរួមក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាយុត្តិធម៌ និងសាលាបឋមសិក្សាសំណាងព្រះស្រីនៅថ្ងៃនេះជាមួយនឹងវត្តមានរបស់ឯកឧត្តមងួនរតនៈអភិបាលរងខេត្តបាត់ដំបង។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ទីរអប់រំ យុវជន និង កីឡាខេត្តបាត់ដំបង និងបុគ្គលិករបស់មន្ទីរដែលបានរៀបចំឲ្យមានពិធីនេះឡើង។

ក្នុងរយៈពេលពីរទស្សវត្សចុងក្រោយនេះបន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងកិច្ចកសាងនិងអភិវឌ្ឍន៍ប្រទេសឡើងវិញរហូតបានក្លាយជាប្រទេសមួយដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ច រីកចំរើនក្នុងតំបន់អាស៊ាន។ ជាមួយគ្នានេះផងដែរ វិស័យអប់រំបានបន្តរីកចំរើនទាំងបរិមាណ និងគុណភាពពីមួយឆ្នាំទៅមួយឆ្នាំ។

ខ្ញុំសូមធ្វើការកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល កម្ពុជាក្នុង ការកែលម្អវិស័យអប់រំ។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំថាជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុនបាន និងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាតាមរយៈការជួយសាងសង់សាលារៀន ក៏ដូចជាបណ្តុះបណ្តាលគ្រូបង្រៀនជាដើម។

បច្ចុប្បន្ន ចំនួន សាលាបឋមសិក្សាក្នុងប្រទេសកម្ពុជាមានប្រមាណ ៦,៩០០ដែលក្នុងនោះ៧៥ភាគរយត្រូវដាក់ឲ្យដំណើរការពីរវេន។ ជាងនេះទៅទៀត អគារសិក្សាខ្លះៗនៃសាលាទាំងនេះបានហួសអាយុកាលប្រើប្រាស់ ហើយត្រូវធ្វើការសាងសង់ឡើងវិញ ដើម្បីសុវត្ថិភាព របស់សិស្សានុសិស្ស។

ខ្ញុំបានទទួលដំណឹងថាដោយសារកង្វះថ្នាក់រៀនសិស្សានុសិស្សនៅសាលាបឋមសិក្សាយុត្តិធម៌និងសាលាបឋមសិក្សាសំណាងព្រះស្រីត្រូវអង្គុយប្រជ្រៀតគ្នានៅក្នុងថ្នាក់រៀន។ ជាងនេះទៅទៀត អគារខ្លះត្រូវបានបំផ្លាញដោយខ្យល់ខ្លាំង និង ភ្លៀងធំផងដែរ។

ឥឡូវនេះអគារសិក្សាថ្មីដែលមាន៦បន្ទប់និងបន្ទប់អនាម័យក្នុងសាលាបឋមសិក្សាយុត្តិធម៌ និងអគារសិក្សាថ្មីដែលមាន៤បន្ទប់ និង បន្ទប់អនាម័យក្នុងសាលាបឋមសិក្សាសំណាងព្រះស្រីត្រូវបានសាងសង់រួចរាល់ហើយ ហើយក្មួយៗសិស្សានុសិស្សទាំងអស់អាចសិក្សានៅក្នុងអគារសិក្សាថ្មីនេះប្រកបដោយសុវត្ថិភាព និងផាសុខភាព។

ខ្ញុំសង្ឃឹមថាសិស្សានុសិស្សនៃសាលាបឋមសិក្សាយុត្តិធម៌ និងសាលាបឋមសិក្សាសំណាងព្រះស្រីទាំងអស់នឹងរីករាយជាមួយការរៀនសូត្រនៅក្នុងថ្នាក់រៀនថ្មីដែលមានបរិស្ថានសិក្សាល្អប្រសើរនេះ ដូចនេះសូមជួយថែរក្សាអគារទាំងនេះ ឲ្យបាននៅគង់វង្សល្អ ទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀត នូវទំនាក់ទំនងមិត្តភាពរវាង ប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!